ក្រុមហ៊ុន ស៊ូភើ លីង ហ្វេសិន (ខេមបូឌា) ឯ.ក

SUPER LINK FASHIONS (CAMBODIA) CO., LTD.

ភូមិសូវង្ស ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

Phum Souvong , Khum Ta Ches, Sruk Kampong Tralach, Kampong Chhnang Province

Tel: +855 889277123 / +855 70258650


# កិច្ចព្រមព្រៀង

## រវាងក្រុមហ៊ុន ជាមួយ តំណាងកម្មករ សហជីព

នៅថ្ងៃ០១ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង០៩ និង០០នាទី នៅបន្ទប់ប្រជុំ រោចក្រស៊ូភើលីងហ្វេសិន(ខេមបូឌា)ឯ.កមានបើកកិច្ចប្រជុំរវាងនាយកក្រុមហ៊ុន និងតំណាងកម្មករសហជីពស្តីពីការព្យួរការងារកម្មករកម្មការនី នៅផ្នែកមួយចំនួនមានផ្នែកឃ្លាំងអំបោះ ផ្នែកប៉ាក់ ផ្នែកបោកគក់ ផ្នែកឃ្លាំងផ្ទាំងអាវ ផ្នែកផុង ផ្នែកដេរ ផ្នែកពិនិត្យ ផ្នែកអ៊ុត ផ្នែកវេចខ្ចប់ ចំនួនសរុប ២៦៦នាក់ ស្រី ១៤៦នាក់ រយៈពេល ៦១ថ្ងៃ ចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣។ ដោយមូលហេតុនៅរដូវកាលនេះរោងចក្រយើងខ្ញុំពុំសូវមានការបញ្ជាទិញនិងសម្ភារៈមិនគ្រប់គ្រាន់ក្នុងការផលិត។

ក្រោយពីបានពិភាក្សាជាមួយភាគីតំណាងកម្មករនិងសហជីពរួចមកជាលទ្ធផលគឺរោងចក្រផ្តល់ជូន ៣០ ដុល្លាក្នុងមួយខែ។ រោងចក្រនឹងធ្វើការបើកប្រាក់ឧបត្ថម្ភសំរាប់ការព្យួរកិច្ចសន្យាការងារ រៀងរាល់១ខែ១ដងនៅថ្ងៃទី១០។

ប្រសិនជាមានការបញ្ជាទិញឡើងវិញក្នុងកំឡុងពេលនៃការព្យួរការងារនេះ រោងចក្រនឹងជម្រាបជូនកម្មករទាំងអស់អោយមកធ្វើការជាធម្មតាវិញ។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១០ និង០០នាទី នាថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយ។

**បានឃើញ និងឯកភាព**

| តំណាងសហជីព | តំណាងប្រតិភូបុគ្គលិក | នាយកក្រុមហ៊ុន |
|---|---|---|
| | | Liu Hua Ping |

Cheng

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ស៊ុបពើ លីង ហ្វេសិន (ខេមបូឌា) ខ.ក
SUPERLINK FASHIONS (CAMBODIA)
CO., LTD.
KINGDOM OF CAMBODIA

CamScanner